**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៩៨/០០៨/២០០៥

ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៧២/០០៤/២០០៥ កបធ.ច

ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២០២/០៧០៥/ពស/នវ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយប្រធានព្រឹទ្ធសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីផ្ទុយនឹងមាត្រា ១១១ ថ្មី (មួយ) វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ប្រកាស ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**